# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ សកម្មភាពរបស់លោក ផាន-វុឌ្ឍី ក្លែងបន្លំជាអ្នកមានបុណ្យ ហើយប្រមាថមើលងាយព្រះសង្ឃ ។

www.hoksavann.org

ថ្ងៃទី២ តុលា ២០១១



លើកមុនយើងបានវិភាគម្តងរួចហើយ អំពីសកម្មភាពរបស់លោក ផាន-វុឌ្ឍី នៅវត្តទួលព្រះរាជា ឃុំពោបាន ស្រុកកោះធំ ខេត្តកណ្តាល ប្រទេសកម្ពុជា ។ ដំបូងលោក ផាន-វុឌ្ឍី តាំងខ្លួនជាសម្តេចជួន-ណាតដឹងជាតិ ក្រោយពេលដែលទាញមនុស្សឲ្យជឿលែងបានទៀត ក៏តាំងខ្លួនជាព្រះសីអារ្យមេត្រីយ៍ ហើយក្នុងពេលថ្មីៗនេះ បានតាំងខ្លួនជាព្រះពុទ្ធអង្គតែម្តងដោយហៅខ្លួនឯងថា តថាគត ក្នុងខ្សែអាត់ថតសម្លេង និងតាមវីដេអូ ។

ក្រោយពេលដែលមន្ត្រីសង្ឃទៅគំរាមមិនឲ្យធ្វើអ្វីខុសពីធម៌វិន័យរបស់ព្រះពុទ្ធសាសនាមានមិនឲ្យបំបួសសង្ឃជាដើម លោក ផាន-វុឌ្ឍី ជាគ្រហស្ថមិនហ៊ានបំបួសព្រះសង្ឃទៀតឡើយ ។ តាមរយៈវីដេអូ គេឃើញលោក ផាន-វុឌ្ឍី បំបួសព្រះសង្ឃឲ្យស្លៀកសពាក់ស ។ ដូច្នេះចាប់ពីពេលនេះតទៅ ទំនងជាឈប់ឲ្យគេធ្វើកឋិនទៀតហើយ ។ ការធ្វើកឋិនពីមុនក្តី ទោះបីពេលនេះធ្វើក្តី មិនឡើងជាកឋិនឡើយ មិនបានកឋិនឡើយ ព្រោះមិនត្រឹមត្រូវតាមពុទ្ធានុញ្ញាត ។

គួរអនិច្ចាមួយទៀត លោក ផាន-វុឌ្ឍី បានពោលតិះដៀលព្រះសង្ឃខ្មែរទាំងមូល ជាពិសេសមន្ត្រីសង្ឃ ថាគ្មានតម្លៃអ្វីទេ គេថ្វាយបង្គំដោយសារយកស្បង់ចីពរព្រះមកពាក់ ចំណែកខ្លួនគាត់វិញទើបជាអ្នកមានបុណ្យ ។ ការពោលតិះដៀលព្រះសង្ឃដែលបួសត្រឹមត្រូវតាមធម៌វិន័យ មានទោសធ្ងន់ណាស់តាមផ្លូវព្រះពុទ្ធសាសនា ។ ការកាន់ព្រះពុទ្ធសាសនា គឺប្រតិបត្តិតាមធម៌វិន័យពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ដូចពុទ្ធសាសនិកជនគោរពតាមព្រះពុទ្ធដីកានៃព្រះសមណគោតមដែលមានគម្ពីរព្រះត្រៃបិដកជាគោល ចំណែកលោក ផាន-វុឌ្ឍី សំអាងអ្វីថាខ្លួនជាអ្នកមានបុណ្យ រហូតតាំងខ្លួនជាព្រះពុទ្ធទៀត ។ តាមការសង្កេតមើល រូបភាពមួយសន្លឹក ឃើញរូបលោក ផាន-វុឌ្ឍី អង្គុយលើផ្កាឈូកអណ្តែតលើពពក ហើយនៅខាងក្រោមមានរូបភាពនាងគង់-ស៊ីអ៊ីមឈរជាពីរជួរអមជាសាវក ។ នេះបញ្ជាក់ថា អ្នកជំនួយការមានបច្ចេកទេសខាងកុំព្យូទ័រដកស្រង់រឿងគង់-ស៊ីអ៊ីម ដែលគេប្រឌិតនៅហុងកុង មកលើកដំកើងលោក ផាន-វុឌ្ឍី ជាព្រះសមណគោតម ហើយព្រះម៉ែគង់-ស៊ីអ៊ីមជាសាវក ។

យើងជាអ្នកសិក្សាតាមគម្ពីរព្រះត្រៃបិដក អដ្ឋកថាដីកា នេះមកស្តាប់លោក ផាន-វុឌ្ឍី និយាយ មិនដឹងជាគាត់ចង់និយាយថាម៉េច ព្រោះមិនចូលក្នុងគម្ពីរព្រះពុទ្ធសាសនាសោះ ព្រោះគាត់ទើបអាយុបានជាង៣០ឆ្នាំ សិក្សាផ្លូវលោកនិងផ្លូវធម៌បានតិចម៉្លោះហើយនិយាយព្រះពុទ្ធសាសនាមិនត្រូវ ក្លាយជាមនុស្សរវើរវាយនិយាយគ្មានការពិត ដូចជានិយាយថា ព្រះបង្កើតទឹកដីភ្លើងខ្យល់ និងបង្កើតកូនបាន១៨សែនកោដិ ។ តើព្រះអង្គណាបង្កើតវត្ថុទាំងនោះ ហើយព្រះពុទ្ធបានលះបង់កាមកិលេសអស់ហើយ ហេតុអ្វីបានជាព្រះពុទ្ធបង្កើតកូនរហូតដល់១៨សែនកោដិ ? គាត់ពោលថា គាត់ហោះទៅស្ថានព្រហ្ម ឈ្មោះវិរសណព្រហ្ម គឺគាត់ទៅដោយឫទ្ធិ អ្នកគ្មានឫទ្ធិទៅពុំបានឡើយ ទំនងជាជិះទូកថត ព្រោះឮច្រវាចែវ ហើយបច្ចេកទេសកុំព្យូទ័រធ្វើដូចជាហោះ ដូចភាពយន្តដែលគេធ្លាប់ធ្វើក្នុងរឿងផ្សេងៗ ។ គាត់ដើរតាមជ្រលងភ្នំជាមួយសហការីពីរបីនាក់ មកដល់កន្លែងមួយគាត់ពោលថា កន្លែងនេះព្រះពុទ្ធយាងមកសំដែងធម៌ ហើយកន្លែងនោះ ព្រះឥន្ទធ្លាប់មកប្រជុំគ្នា ។ តាមប្រវត្តិព្រះពុទ្ធសាសនា គ្មានឃើញព្រះពុទ្ធមកសំដែងធម៌នៅប្រទេសកម្ពុជាឡើយ ។

ការនិយាយរវើរវាយជារឿងផ្ទាល់ខ្លួនរបស់គាត់ ប៉ុន្តែបញ្ហាមួយដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណជនខ្មែរ គឺការឃោសនាលក់របស់របរផ្សេងៗ ដែលថាជាវត្ថុស័ក្តិសិទ្ធិ ។ គ្នាគាត់ពីរបីនាក់រួមជាមួយគាត់ផង នាំគ្នាធ្វើដំណើរទៅតាមជ្រោះភ្នំ ទៅធ្វើថ្នាំ ទៅយកត្បូងហៅថាកែវមុនីទិព្វ និងព្រះពុទ្ធរូប ដែលកាលទេវតាច្បាំងគ្នាបានទុកឲ្យគាត់ ។ តាមរយៈវីដេអូឃើញគាត់កាយដីខ្សាច់តាមជ្រលងភ្នំ ឃើញវត្ថុស័ក្តិសិទ្ធិទាំងនោះ ។ ក្នុងសម័យកុំព្យូទ័រនេះ មនុស្សមិនល្ងង់ទេ វត្ថុទាំងនេះពិតជាស្តាយយកទៅកប់ ។ ពេលកប់ក្នុងខ្សាច់មិនថតទេ លុះកប់រួចពេលទៅកាយយកទើបថត ។ អ្នកជឿគាត់ ចំពោះអ្នកដែលគ្មានការពិចារណាប៉ុណ្ណោះ ។ ព្រះពុទ្ធរូបតូចធំច្រើនគង់លើផ្កាឈូក ហើយមានស្នាមខ្មៅមួយជុំត្រង់ចន្លោះចិញ្ចើម គឺជាសិល្បៈជាងចនាបថចិន ។ របស់ដែលមានលក់នៅបរទេស មានថ្មរាងតូចមូល គេថាជាពងនាគ, ពូថៅទិព្វ (ដាវនេះគេឃើញលក់នៅប្រាសាទបន្ទាយស្រី និងនៅលើភ្នំគូលែន) ជាដើម ។ ការលក់វត្ថុទាំងនេះជារបៀបធ្វើជំនួញ ដោយយកព្រះពុទ្ធសាសនាជាមធ្យោបាយ ។

តាមការទេសនារបស់គាត់តាមទូរស័ព្ទ គ្មានហេតុផលដែលគួរយកមកពិចារណាសោះឡើយ មានតែអួតខ្លួនគាត់ជាអ្នកមានបុណ្យ រហូតតាំងខ្លួនជាព្រះពុទ្ធ ដោយប្រើពាក្យថាតថាគត ហើយត្មះតិះដៀលព្រះសង្ឃព្រះពុទ្ធសាសនា ដែលបួសត្រឹមត្រូវតាមធម៌វិន័យព្រះពុទ្ធសាសនាថែមទៀត ។ គាត់តាំងបុរសម្នាក់នៅសហរដ្ឋអាមេរិកថាជាព្រះអរហន្ត សូម្បីប្រពន្ធគាត់ក៏ថាជាព្រះអរហន្តដែរ ។ ការធ្វើបង្គន់១០០ហើយឃោសនាថា នឹងធ្វើព្រះវិហារបណ្តោយកន្លះគីឡូម៉ែត្រ (៥០០ម) ។ ការធ្វើហួសពីសេចក្តីត្រូវការនេះ ជាការបំផ្លាញថវិកាខ្មែរ ជាភាពរវើរវាយតាមតែការនឹកឃើញ ។

អដ្ឋង្គិកមគ្គ ប្រែថាមគ្គប្រកបដោយអង្គ៨ រួមមកបានដល់ទានសីល ភាវនា ឬសីលសមាធិបញ្ញា ជាផ្លូវចេញចាកទុក្ខមាន

ជាតិទុក្ខជាដើម មិននាំគ្នាសិក្សាឲ្យយល់សេចក្តី ហើយប្រតិបត្តិតាម ពេលដែលជួបព្រះពុទ្ធសាសនាមានគម្ពីរព្រះត្រៃបិដកជាគោល បែរជាមានមនុស្សមួយភាគតូចនាំគ្នាជឿអបីយ៍ជំនឿ ពុំមែនជាធម៌ជាវិន័យ ឃោសនាប្រាសចាកសេចក្តីពិត ។ គ្មានវត្ថុស័ក្តិសិទ្ធិណាមួយជួយមនុស្សឲ្យអស់ទុក្ខ ក្រៅពីប្រតិបត្តិតាមមគ្គប្រកបដោយអង្គ៨នេះឡើយ ។

ពុទ្ធសាសនិកជនខ្មែរមុននឹងជឿអ្វីមួយ គប្បីពិចារណាឲ្យបានល្អិតល្អន់ បើសង្ស័យយល់ពុំច្បាស់ សូមសួរអ្នកប្រាជ្ញព្រះពុទ្ធសាសនាដើម្បីបញ្ជាក់បន្ថែម ។ ក្នុងកាលាមសូត្រ ព្រះពុទ្ធជាម្ចាស់បានបញ្ជាក់ច្បាស់ណាស់ថា កុំឲ្យជឿអាការៈ១០យ៉ាង មានមិនឲ្យជឿនូវពាក្យដែលនិយាយតៗគ្នា កុំឲ្យជឿអាការៈខាងក្រៅដោយកាយវិការដោយពាក្យសំដីជាដើម ។ ក្នុងមហាបទេស៤យ៉ាង ត្រូវយកពាក្យសំដីគេនិយាយមកផ្ទៀងមើល តើត្រឹមត្រូវតាមធម៌វិន័យរបស់ព្រះពុទ្ធឬទេជាដើម ។ ក្នុងវិបត្តិឧបាសក៥យ៉ាង កុំឲ្យជឿមង្គលភ្ញាក់ផ្អើល ដូចជឿថាព្រះផុស ជឿថ្ងៃខែឆ្នាំថា ឲ្យសុខឲ្យទុក្ខ ជឿថាអ្នកមានបុណ្យកើតឡើងហើយជាដើម ។ គេឃើញពុទ្ធបរិស័ទដែលជឿ ធាន-វុឌ្ឍី មានប្រុសមានស្រីភាគច្រើនមនុស្សចាស់ដេកផ្កាប់មុខ ឲ្យធាន-វុឌ្ឍី ដើរជាន់ត្រង់ចង្កេះជាបន្តបន្ទាប់គ្នា ពុំដឹងជាដើម្បីអ្វីទេ ។ ធាន-វុឌ្ឍី បានដឹងខ្លួនឯងហើយថា មានគេមិនជឿគាត់ ជាពិសេសអ្នកនៅក្បែរៗវត្ត ។ តាមពត៌មានថា លោក ធាន-វុឌ្ឍី មានប្រពន្ធនៅផ្សារសែរ៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ ហើយបានសង់វិទ្យាមួយឲ្យបងប្អូននៅឃុំចំប៉ា ស្រុក ខេត្ត ដដែល ។ តាមព្រះពុទ្ធសាសនា ឲ្យជឿកម្មផលដែលខ្លួនកសាង ជឿការត្រាស់ដឹងរបស់ព្រះពុទ្ធ ជឿព្រះត្រៃបិដកដែលពិភពលោកទទួលស្គាល់ ។

យើងសូមផ្សាយមេត្តាករុណាចិត្តចំពោះធាន-វុឌ្ឍី សូមពិចារណា គប្បីបញ្ឈប់នូវអំពើបាបកម្មនេះ កុំធ្វើតទៅទៀត ដើម្បីកុំឲ្យព្រះពុទ្ធសាសនាសៅហ្មង ហើយសូមអាណិតអាសូរដល់ពុទ្ធបរិស័ទខ្មែរ ដែលកំពុងមានជីវភាពក្រីក្រ ខំបេះពីមាត់ពីកយកបច្ច័យទៅបូជានៅកន្លែងដែលមិនគួរបូជា ។ នាំឲ្យពុទ្ធបរិស័ទខ្មែរយល់ខុស ដោយការបង្កើតធម៌ថ្មខុសពីព្រះត្រៃបិដក ។ ផ្លូវអាណាចក្រវិញ អំពើនេះចាត់ជាការបំផុសបំផុលសន្តិសុខសាធារណៈ ធ្វើឲ្យប្រជាពលរដ្ឋជ្រួលច្របល់មានជំនឿខុសត្រូវមានទោស ។ យើងយល់ថា រាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ន ក៏ចង់ឲ្យព្រះពុទ្ធសាសនាមានភាពស្អាតបរិសុទ្ធ ជាជំនួយដល់ផ្លូវអាណាចក្រ ដើម្បីឲ្យប្រទេសកម្ពុជាបានសុខសន្តិភាព ប្រកបដោយសេចក្តីសុខចំរើន ។៚

*　　*

*